PTI0073

# សម្ភាសជាមួយឈ្មោះ អ៊ុក ទុំ ភេទប្រុស អាយុ ៥៥ឆ្នាំ

មុខងារខ្មែរក្រហមៈ អ្នកសែងរបួស

មុខងារបច្ចុប្បន្នៈ ធ្វើស្រែ

មានស្រុកកំណើតនៅៈ ភូមិទួលកណ្តាល ឃុំព្រៃខ្វា ស្រុកកោះអណ្តែត ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០១:០២:៣៥

ទំព័រ២៤

ប៊ុនថន : អញ្ជើញដឹបូងខ្ញុំសុំអនុញ្ញាតសម្ភាសន៍លោកពូៗអនុញ្ញាតឲ្យខ្ញុំសម្ភាសន៍ទេលោកពូ?

ទុំ : បាទៗ!

ប៊ុនថន : លោកពូឈ្មោះអីដែរលោកពូ?

ទុំ : ខ្ញុំឈ្មោះ អ៊ុក ទុំ ។

ប៊ុនថន : លោកពូអាយុប៉ុន្មានហើយ?

ទុំ : អាយុ៥៥ហើយ ១៩៤៩ ។

ប៊ុនថន : បាទ!លោកពូមានស្រុកកំណើតនៅភូមិឃុំអីដែរលោកពូ?

ទុំ : បាទ!ខ្ញុំនៅភូមិទួលកណ្តាល ឃុំព្រៃខ្វា ស្រុកកោះអណ្តែត ខេត្តតាកែវ ។

ប៊ុនថន : សព្វថ្ងៃលោកពូរស់នៅភូមិឃុំអីដែរ?

ទុំ : រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ប៊ុនថន : បាទ!លោកពូមានបងប្អូនប៉ុន្មាននាក់លោកពូ?

ទុំ : បងប្អូនខ្ញុំ៦នាក់ ។

ប៊ុនថន : បាទ!ស្រីប៉ុន្មាន ប្រុសប៉ុន្មានលោកពូ?

ទុំ : បាទ!ស្រី២នាក់ ប្រុសទាំងអស់ ប្រុស៤នាក់ ។

ប៊ុនថន : លោកពូកូនទីប៉ុន្មានលោកពូ?

ទុំ : ខ្ញុំកូនទី៥ហើយ ។

ប៊ុនថន : ហើយបងប្អូននៅរស់ទេសព្វថ្ងៃ?

ខ្ញុំ ៖ បងប្អូនខ្ញុំស្លាប់ហើយនៅសល់នេះ ស្លាប់ជំនាន់ពតឆ្នាំនោះ ១ម្នាក់គេយកទៅវៃចោល កាលជំនាន់ពតឆ្នាំ ។

ប៊ុនថន ៖ បាទ!ស្លាប់នៅណាវិញលោកតា?

ខ្ញុំ ៖ ស្លាប់នៅកោះអណ្តែតនៅភូមិកំណើតហ្នឹង ។

ប៊ុនថន ៖ អូ!ហើយក្រោយមកទៀត?

ខ្ញុំ ៖ ក្រោយទៀតស្លាប់នឹងជំងឺ គាត់ចាស់ៗហើយ ។

ប៊ុនថន ៖ អញ្ចឹងសព្វថ្ងៃនៅសល់តែតា ហើយ?

ខ្ញុំ ៖ បងប្អូននៅ៤នាក់ទៀតនៅស្រុកនោះ ។

ប៊ុនថន ៖ បាទ!ចុះដែលម៉ោលេងនេះទេតា?

ខ្ញុំ ៖ ដែលៗម៉ោលេង ។

ប៊ុនថន ៖ ហើយតាខស្សាហ៍ទៅលេងស្រុកទេ?

ខ្ញុំ ៖ អត់ដែលបានទៅទេ យូរណាស់ហើយ ។

ប៊ុនថន ៖ អូ!តាំងពីបែក?

ខ្ញុំ ៖ បាទ!យូរណាស់ហើយ ។

ប៊ុនថន ៖ ម៉េចអត់ដែលទៅលេងអញ្ចឹងតា?

ខ្ញុំ ៖ វាទាក់ទិននឹងម្យ៉ាងយើងកំពុងអត់អញ្ចឹងខំរកហើយ ម្យ៉ាងទៀតបងប្អូនម៉ោពីស្រុកម៉ោលេងនេះអស់ហើយ ។

ប៊ុនថន ៖ បាទ!ហើយលោកតាបានរៀនសូត្រដល់ថ្នាក់ណាដែលលោកតា?

ខ្ញុំ ៖ ខ្ញុំរៀនថ្នាក់ទី៧ ពីសង្គមចាស់ ។

ប៊ុនថន ៖ នៅសាលាណាលោកតា?

ខ្ញុំ ៖ សាលានៅយើងនៅស្រុកកោះអណ្តែត ។

ប៊ុនថន ៖ បាទ!លោកតាឈប់រៀនហើយ ហើយលោកតាធ្វើអីទៀតលោកតា?

ខ្ញុំ ៖ ខ្ញុំឈប់រៀនហើយ ខ្ញុំនៅផ្ទះដោយជីវភាពគ្រួសារក្រជួយធ្វើការងារឪពុកម្តាយ ។

ប៊ុនថន ៖ បាទ!គាត់នៅរស់ទេសព្វថ្ងៃ ឪពុកម្តាយលោកតា?

ខ្ញុំ ៖ ឪពុកម្តាយស្លាប់អស់ហើយ ស្លាប់ជំនាន់៧៨នោះ ។

ប៊ុនថន ៖ គាត់ស្លាប់ដោយសារអីដែលលោកតា?

ខ្ញុំ ៖ គាត់ស្លាប់ដោយសារជំងឺចាស់ៗ ។

ប៊ុនថន : បាទ!ស្លាប់នៅស្រុកទេលោកពូ?

ខ្ញុំ : ស្លាប់នៅស្រុក ។

ប៊ុនថន : បាទ!កាលនោះមានធ្វើអីខ្លះលោកពូ ក្រៅពីការងារស្រែចំការមានធ្វើអីផ្សេងទេ និយាយពីឪពុកម្ដាយ?

ខ្ញុំ : អូ!ឪពុកម្ដាយគាត់ធ្វើស្រែៗ នឹងរកស៊ីបន្តិចបន្តួចហ្នឹង ។

ប៊ុនថន : ចុះពូនៅយូរទេជាមួយឪពុកម្ដាយ?

ខ្ញុំ : ខ្ញុំនៅបាន២០ឆ្នាំ ជាមួយឪពុកម្ដាយ ក្រោយគេកៀរជំនាន់យើងនេះហ្នឹងគេប្រមូលម៉ោធ្វើកងចល័តធ្វើអីហ្នឹង ។

ប៊ុនថន : ចុះកាលសម័យសង្គ្រាម៥ឆ្នាំនោះ ពូបានចូលកងចល័តឬនៅលោកពូ?

ខ្ញុំ : មិនទាន់បានចូលផងជំនាន់ហ្នឹង កាលនោះស្រែចំការគេមិនទាន់រៀបចំណា អ្នកណាទៅក៏ធ្វើអ្នកណាមិនធ្វើក៏ហីទៅ នៅក្នុងភូមិគេឯងទៅ ។

ប៊ុនថន : បាទ!អញ្ចឹងសម័យសង្គ្រាម៥ឆ្នាំលន់ ណុល សង្គ្រាមជាមួយលន់ ណុល ហ្នឹងពូនៅក្នុងភូមិទេ?

ខ្ញុំ : បាទ!អាហ្នឹងគ្រាន់តែកងគេឲ្យយើងធ្វើស្នាក់ការស្នាក់អីជួយទៅ ពួកអប់រំហ្នឹង ។

ប៊ុនថន : បាទ!

ខ្ញុំ : ធ្វើស្នាក់ការប្រចាំការសែងរបួស សែងអីគេវៃគ្នាហ្នឹង ។

ប៊ុនថន : អូ!ឆ្នាំប៉ុន្មានពូចូលកាលនោះ?

ខ្ញុំ : ចាំមើលឆ្នាំ៧២-៧៣ហ្នឹង ។

ប៊ុនថន : បាទ!

ខ្ញុំ : គេវៃណា ទៅជួយសែងរបួសសែងអី ស្នាក់ការរៀបចំស្នាក់ការ ។

ប៊ុនថន : កាលនោះពូចូលកងហើយ៧០?

ខ្ញុំ : ចូលហើយ ប៉ុន្តែគ្រាន់តែនៅយុវជនភូមិនៅឡើយទេ ។

ប៊ុនថន : កាលហ្នឹងគេជ្រើសរើសឬក៏យើងស្ម័គ្រចិត្ត?

ខ្ញុំ : កាលហ្នឹងឧទាហរណ៍បើនិយាយថាជ្រើសរើសក៏ថាបាន បើនិយាយថាមិនជ្រើសរើសក៏ថាបាន គ្មានរៀបឲ្យចំទៅណា ឧទាហរណ៍ថាក្មេងៗរៀបចំស្នាក់ការបើសមរភូមិណាមួយគេប្រមូលហើយ តាមភូមិ ម៉ាភូមិអញ្ចឹងគេចែកគ្នាទៅហើយទៅ១ដងម្នាក់ៗ ។

ប៊ុនថន : បាទ!ខាងភូមិយើងអ្នករៀបចំ ពូ?

ខ្ញុំ : បាទ!ខាងភូមិយើងរៀបចំ។

ប៊ុនថន : បាទ!រៀបចំគេបែងចែកម៉េចទៅពូ គេបែងចែកជាកម្មករប៉ុន្មាននាក់ៗអីអញ្ចឹង?

ខ្ញុំ : នៅភូមិ គេហៅភូមិហ្នឹងអាយុប៉ុន្មានៗអញ្ចឹង រៀបចំស្នាក់ការបន្តម៉ោភូមិទល់មន្ទីរពេទ្យទៀត ជំនាន់នេះនិយាយរួមប្រជាជនទូទាំងប្រទេសនៅក្នុងតំបន់ខ្មែរក្រហមសុទ្ធតែអញ្ចឹងទាំងអស់គ្នាហ្នឹង។

ប៊ុនថន : បាទៗ!

ខ្ញុំ : ខ្លះធ្វើខាងនេះទៅ ខ្លះធ្វើខាងនោះទៅ ប្រចាំការទីស្នាក់ការ ខ្លះសែងរបួសសែងអីទៅ។

ប៊ុនថន : បាទ!កាលហ្នឹងមានវ៉ៃគ្នាដែលលោកពូ?

ខ្ញុំ : ចុះវ៉ៃជំនាន់ លន់ ណុល មិនវ៉ៃគ្នា។

ប៊ុនថន : បាទ!វ៉ៃនៅណាវិញលោកពូ?

ខ្ញុំ : វ៉ៃនៅខាងតាកែវនោះ។

ប៊ុនថន : ខាងទីរួមខេត្ត?

ខ្ញុំ : បាទ! តាកែវ ឧទាហរណ៍គេវ៉ៃតាមស្រុក តាមទីតាំងទាហាន លន់ ណុល រស់នៅ។

ប៊ុនថន : បាទ!

ខ្ញុំ : អញ្ចឹងគេមិនរើសប្រជាជននៅតាមភូមិ យកទៅធ្វើស្នាក់ការ ដល់ពេលសមរភូមិគេត្រូវការរៀបស្នាក់ការសម្រាប់បញ្ជូនអ្នករបួសអ្នកអីហ្នឹង។

ប៊ុនថន : បាទៗ!

ខ្ញុំ : មានអ្នកស្លាប់មានអីហ្នឹង។

ប៊ុនថន : ចូលជំបូងនៅណាវិញលោកពូ?

ខ្ញុំ : បាទ!?

ប៊ុនថន : ចូលជំបូងចូលនៅណាវិញ?

ខ្ញុំ : ខ្ញុំនៅតាកែវនោះ ស្រុកកំណើតខ្ញុំនៅតាកែវ។

ប៊ុនថន : បាទ!ចូលនៅភូមិ ឃុំអីដែលលោកពូនៅតាកែវ?

ខ្ញុំ : នៅឃុំកោះអណ្ដែតដដែលហ្នឹង ស្រុកកោះអណ្ដែតដដែលហ្នឹង។

ប៊ុនថន : ចុះម៉ាកងពូ ប៉ុន្មាននាក់កាលហ្នឹង?

ខ្ញុំ : វាខ្លះគេរៀបចំក្រុម នៅក្នុងភូមិកាលពីដើមគេរៀបចំក្រុម ដូចតែយើងឥឡូវហ្នឹង គេរៀបចំមេក្រុមៗគេ ហ្នឹង។

ប៊ុនថន : បាទៗ!

ទុំ : អញ្ចឹងឧទាហរណ៍ថា ត្រូវក្រុមណាត្រូវប្រចាំការ គេប្រាប់ក្រុមហ្នឹងទៅប្រចាំការរយៈពេលប៉ុន្មាន មាអាទិត្យអីត្រូវដូរគ្នា ដូរគ្នាម៉ោវិញម៉ោ ។

ប៊ុនថន : បាទៗ!

ទុំ : អាអ្នកថ្មីទៅទៀតទៅ ។

ប៊ុនថន : បាទ!គេបែងចែកក្រុមហើយ មានប្រធានក្រុមទៀតទៅ?

ទុំ : បាទ!អាហ្នឹងគេនាំតាមរយៈប្រធានភូមិ ហើយយុវជនយុវនារីភូមិហ្នឹងគេរៀបចំស្នាក់ការតាមភូមិ ទៅដល់សមរភូមិគេចាប់ផ្ដើមរៀបស្នាក់ការ ។

ប៊ុនថន : ហើយដូចថាគេមានកំណត់អាយុអីទេ ពេលគេរើសចូល?

ទុំ : គេអត់កំណត់ទេ ឧទាហរណ៍ថាវ័យចាស់ល្មមថាយើងសែងមនុស្សរួច ប៉ុនៗនេះអត់ កើតទេ ដល់ពេញជំទង់ប៉ុនៗនោះ ។

ប៊ុនថន : បាទ!

ទុំ : ករណីជំនាន់ហ្នឹងទាំងអស់គ្នានេះប្រមូលទៅ ទោះបីចង់ មិនចង់ក៏ត្រូវតែទៅ ។

ប៊ុនថន : បាទៗ!

ទុំ : តាមពិតយើងទាំងអស់គ្នាសុទ្ធតែខ្លាច ភូមិណាក៏ខ្លាចដែរបើសុទ្ធតែផ្ទោងដាក់គ្នា ក្ដុងក្ដាំង គេទម្លាក់យើងធ្វើម៉េចបើគេកែនឲ្យទៅ បើយើងមិនទៅក៏ត្រូវតែទៅ ។

ប៊ុនថន : ពូនៅខាងសែងរបួសពូ?

ទុំ : បាទ!នៅខាងសែងអ្នករបួស សែងរបួសជួនកាលគេត្រូវការគ្រាប់រំសេវអី យើងគេឲ្យយកគ្រាប់ និយាយទៅអ្នកប្រចាំការស្នាក់ការ ត្រូវការម៉ាចប់វាត្រូវកាសែងរបួសក៏សែង ត្រូវការបញ្ជូនគ្រាន់គេបញ្ជូនគ្រាប់គេបញ្ជូន តាមថ្នាក់ៗកងៗតគ្នាទៅ ។

ប៊ុនថន : បាទ!ហើយពូបញ្ជូន ហើយសែងអ្នករបួសពីណាទៅណាខ្លះលោកពូនៅចាំទេ ពីកន្លែង ពូទៅមុខព្រួយ?

ទុំ : កន្លែងហ្នឹងពិបាកចាំណាស់វាយូរយារណាស់ហើយ ចង់និយាយថាស្រេចទីតាំងកន្លែងណាគេរៀបចំកន្លែងហ្នឹង ឧទាហរណ៍ថាវ៉ៃនៅកន្លែងសាលាស្រុកអញ្ចឹង រៀបចំហ្នឹងរហូតទៅដល់កន្លែងមន្ទីរពេទ្យគេ ។

ប៊ុនថន : បាទ!

ខ្ញុំ : បាទ!ខ្លះយកពីសមរភូមិ ខ្លះបេះតែតគ្នាមក ខ្លះក៏ជិតខ្លះឆ្ងាយ បេះតៗគ្នាមក កង១ ដុំៗទៅ ។

ប៊ុនថន : ចុះមានបានហាត់រៀនទេពូ ហាត់ដូចថារបៀបដូចថាវិធីសែងរបួស វិធីដឹកជញ្ជូនអី អញ្ចឹងមានហាត់ទេលោកពូ?

ខ្ញុំ : អត់ទេ!អត់ហាត់ទេ បើសម័យនោះឧទាហរណ៍ទី១បញ្ហាគ្រាប់ផ្លោង ទី២ បញ្ហាយន្តហោះទម្លាក់ អញ្ចឹងគេគ្រាន់តែណែនាំថា តាមស្នាក់ការមួយៗនៅទីតាំងផ្សេង ការពារ ដូនកាលវ៉ៃគ្នាផាប់ ដូនកាលគ្រាប់ផ្លោងនៅក្រោយ ឬក៏ដូនកាលក៏យន្តហោះទម្លាក់ អញ្ចឹងជំនាន់អាមេរិចទម្លាក់ទាំងយប់ទាំងថ្ងៃហ្នឹងគេធ្វើការពារ បើវាមានគ្រាប់ផ្លោងគេ ចូលបួង់សេទៅ អត់មានគ្រាប់ផ្លោងចេញម៉ោបិញម៉ោ យន្តហោះទម្លាក់ក៏អញ្ចឹងដែរ ។

ប៊ុនថន : ខាងណាប្រធាន ខាងណាអ្នកណែនាំពូ?

ខ្ញុំ : ខាងស្រុក គេរៀបចំពីដើមគេរៀបចំប្រធានៗតាមភូមិ តាមស្រុកគេ តាមប្រធានគេ ដូចយើងរៀបចំភូមិពីដើមអញ្ចឹង ។

ប៊ុនថន : បាទ!

ខ្ញុំ : រៀបចំពីលើ ពីក្រោមអញ្ចឹងទៅវាបេះតែតៗគ្នាទៅ ។

ប៊ុនថន : កាលហ្នឹងគេហៅស្រុកអី ស្រុកកោះអណ្ដែតគេហៅអីផ្សេង?

ខ្ញុំ : អាហ្នឹងស្រុកកោះអណ្ដែតពីដើមគេហៅ ស្រុក១០៨ ជំនាន់៧៥ហើយគេហៅ ១០៨ ។

ប៊ុនថន : បាទៗ!ខាងស្រុកពីណាគណៈស្រុកលោកពូកាលហ្នឹង?

ខ្ញុំ : គណៈស្រុកកាលហ្នឹង តាម៉ន មួយតាម៉នហ្នឹងគាត់ស្លាប់ជំនាន់៧៣ហើយ ។

ប៊ុនថន : ចុះក្រោយម៉ោលោកពូ?

ខ្ញុំ : ក្រោយម៉ោខ្ញុំឡើងទៅលើហួសហើយ ។

ប៊ុនថន : កាលហ្នឹងតំបន់ប៉ុន្មានវិញលោកពូ?

ខ្ញុំ : តំបន់១៣ ។

ប៊ុនថន : តំបន់១៣មានស្រុកអីខ្លះលោកពូ?

ខ្ញុំ : ភ្លេចអស់ទៀតវាយូរពេកហើយ តំបន់ៗ១៣ ប៉ុនស្រុកៗពីដើមគេហៅស្រុកគិរីវង់ ស្រុកត្រាំង ស្រុកព្រៃកប្បាស ចង់ភ្លេចអស់ហើយ ស្រុកកោះអណ្ដែត ។

ប៊ុនថន : អាហ្នឹងម៉ាជនៀរខាងតំបន់១៣ហ្នឹង?

ខ្ញុំ : បាទ!ខាងតំបន់១៣ហ្នឹង តាកែវជាប់ជាមួយព្រំដែនយួន ។

ប៊ុនថន : អញ្ចឹងពូនៅខាងដឹកជញ្ជូននោះខាងទ័ពទេពូ?

ខ្ញុំ : បាទ!តាមពិតយើងមិនមែនចាំតែទ័ពទេ ព្រោះអាហ្នឹងគេហៅថាស្នាក់ការ ស្នាក់ការគេប្រមូលប្រជាពលរដ្ឋនៅតាមភូមិ ឲ្យយុវជនឬយុវនារីដែលពេលកម្លាំងល្មមសែងបានអ្នករបួសនោះណា៎ ។

ប៊ុនថន : បាទ!

ខ្ញុំ : អាហ្នឹងគេប្រមូលឲ្យជួយសមរភូមិនេះ ពេលបើកសមរភូមិហ្នឹងគេប្រមូលទៅហើយជួយស្នាក់ការអ្នករបួសអ្នកអីហ្នឹង ។

ប៊ុនថន : បាទ!គេអត់ទាន់បែងចែកច្បាស់លាស់ទេ?

ខ្ញុំ : អត់ទេ!នៅទេ អ្នកទ័ពគេទ័ពគេផ្សេងសម្រាប់គេវ៉ៃ ប៉ុនយើងដោយឡែកនៅតាមភូមិមានករណីធ្វើស្នាក់ការគេទៅ ។

ប៊ុនថន : កាលហ្នឹងគេមានបែងចែក ដូចថាបែងចែកជាទ័ពអីច្បាស់លាស់ឬនៅពូកាលពូនៅ?

ខ្ញុំ : ខ្ញុំអត់សូវដឹងទេ និយាយរួមការងារ បើការងារជំនាន់នោះ ឧទាហរណ៍ថាបើអ្នកធ្វើដឹងតែប៉ុនហ្នឹងទេ បើគេចោទចេះចុះខ្សែលិចខ្សែកើតប៉ះពាល់ដល់គេ ខ្ញុំអត់នេះដែលហ្នឹងនិយាយរួមយើងដឹងតែតួនាទីគេប្រាប់ឲ្យធ្វើអីធ្វើទៅ ការងារខាងទ័ពខាងគេរៀបចំអីយើងក្តាប់អត់បានទេ ឧទាហរណ៍ថាឲ្យតែគេប្រមូលយើងត្រូវតែទៅ ។

ប៊ុនថន : បាទ!ពូនៅយូរទេ ពូនៅខាងអ្នកសែងអ្នករបួស ខាស្នាក់ការហ្នឹង?

ខ្ញុំ : និយាយរួមនៅទាល់តែយើងចប់៧៥អាហ្នឹង និយាយរួមអាហ្នឹងវាមានករណីឧទាហរណ៍ ថាបើយើងវ៉ៃក្នុងខេត្តយើង អាហ្នឹងវាមកប្រមូលយើងថែមទៀត ប៉ុនបើទៅឆ្ងាយគេឈប់ប្រមូលហើយ អាហ្នឹងមានអ្នកខេត្ត ស្រុកជាប់ភូមិប្រមូលអ្នកហ្នឹងវិញ អញ្ចឹងរៀបចំអញ្ចឹងវិញ ។

ប៊ុនថន : អញ្ចឹងយើងនៅស្រុកណា យើងនៅស្រុកហ្នឹងវិញ?

ខ្ញុំ : បាទ!យើងជួយការងារគេខាងក្រោយហ្នឹងទៅ ហើយយើងអត់ប្រចាំការណ៍ សមរភូមិនៅផុតឆ្ងាយកន្លែងភូមិស្រុកយើង យើងអត់ទាក់ទិនជាមួយទេ ហើយបើករណីដែលឧទាហរណ៍ថាបើសមរភូមិវាជាប់ហ្នឹង អាហ្នឹងគេរៀបចំគេហៅយើងហើយ អញ្ចឹងយើងស្រែធ្វើភ្លឺធម្មតាទៅ អញ្ចឹងមិនមែនជាអង្គភាពផ្តាច់មុខថាឥឡូវនេះទេ នៅតែនៅដឹកជញ្ជូនរហូត អត់ទេ អាហ្នឹងករណីពិសេសឧទាហរណ៍ថាវាជាប់អញ្ចឹងនៅក្នុងខេត្តហ្នឹងគេចេះតែប្រមូលហើយ ។

ប៉ុនថន : បាទ!

ខ្ញុំ : ដើម្បីរៀបចំស្នាក់ការ ។

ប៉ុនថន : បាទ!ចុះបែកឆ្នាំ៧៥ហើយហ្នឹង គេមានបែងចែកអីសារជាថ្មីទៀត?

ខ្ញុំ : អូ!ខ្ញុំក្រោយម៉ោគេឲ្យខ្ញុំម៉ោកងចល័ត កងចល័តបានម៉ោធ្វើទ័ពគេហ្នឹង ធ្វើទ័ពនៅតាកែវហ្នឹង មុនដំបូងគេ ដល់យើងម៉ោភូមិឆ្ងាយៗបាគេឲ្យយើងនៅកងចល័ត នៅកងចល័តគ្មានធ្វើអី ឧទាហរណ៍ថាអាស្នាក់ការហ្នឹងដួលកាលគេយកធ្វើកងចល័ត គេហៅអង្គភាពអីគេមិនដឹងទេ អង្គភាពយុវជនភូមិ ឃុំគេហ្នឹង ប្រមូលជួយ ។

ប៉ុនថន : អញ្ចឹងពូ៧៥ហ្នឹងគេជ្រើសរើសម៉ោពីកងចល័តហ្នឹង ម៉ោទ័ពលោកពូ?

ខ្ញុំ : បាទ!

ប៉ុនថន : កាលហ្នឹងនៅខាងណាវិញលោកពូ?

ខ្ញុំ : ខ្ញុំនៅខាងតាកែវដែរ ។

ប៉ុនថន : ខាងតាកែវ?

ខ្ញុំ : បាទ!

ប៉ុនថន : បាទ!កាលហ្នឹងនៅជាមួយពីណាលោកពូ?

ខ្ញុំ : នៅជាមួយតា វ៉ែន ហ្នឹងគាត់ស្លាប់បាត់ហើយ ។

ប៉ុនថន : អូ!គាត់កងពល?

ខ្ញុំ : បាទ!

ប៉ុនថន : តា វ៉ែន គាត់កងពលលេខ១ពូ?

ខ្ញុំ : មិនមែនទេកងពលទី២ តា ប៊ិត ប្រធានកងពល តាប៊ិតហ្នឹង កាលម៉ាវឹកជាប់គុកស្លាប់បាត់ហើយ ។

ប៉ុនថន : តាប៊ិត ហ្នឹងកាលហ្នឹងគាត់ស្លាប់ដោយសារអីលោកពូ?

ខ្ញុំ : ស្លាប់កាលហ្នឹងដោយសារជនបរទេស ម៉ាជួរក្រោយនេះ ម៉ាជួរភ្នំវល្លិ៍អីនេះ ខ្ញុំក្តាប់អត់សូវបានទេ ខ្ញុំម៉ោនៅនេះហើយប៉ុនក្តាប់បានបែកម៉ោ ៧៩យើងរត់ ។

ប៉ុនថន : ចុះតា វ៉ែន វិញគាត់ស្លាប់ដោយសារអី?

ខ្ញុំ : ស្លាប់ដោយសារជំងឺ ។

ប៉ុនថន : ស្លាប់នៅក្រោយ៧៩នោះទេ?

ខ្ញុំ : បាទ!នៅក្រោយ៧៩បានស្លាប់ ស្លាប់ដោយសារជំងឺឈឺស្តឹកម៉េច ។

ប៊ុនថន : អញ្ចឹងពូ កាលហ្នឹងនៅជាមួយវ៉ែន ខាងកងពលលេខ២ពូ?

ខ្ញុំ : បាទ!កងពលលេខ២ ។

ប៊ុនថន : បាទ!ហើយកាលហ្នឹងពូបែកភ្លាមគេបញ្ជូនពូម៉ោភ្លាម ឬក៏ជ្រើសរើសម៉េចទៅ ។

ខ្ញុំ : កាលយើងចប់ភ្នំពេញហើយ?

ប៊ុនថន : បាទ!

ខ្ញុំ : ចប់ភ្នំពេញខទាហរណ៍គេឲ្យប្រមូលចូលទ័ពអីអញ្ចឹងទៅ កាលហ្នឹងជំនាន់ហ្នឹងគេមិនបំបិទបំបាំងកងទ័ព អញ្ចឹងតាមពិតខ្ញុំមុនដំបូងគេឲ្យចូលកងទ័ព ប៉ុនវាទាក់ទិននឹងរឿងបងគេសម្លាប់កាលជំនាន់ពន្ធាំនោះ អញ្ចឹងគេមិនឲ្យចូលទេ ប៉ះពាល់សមាសភាពល្អ អញ្ចឹងខ្ញុំក៏នៅនេះទៅ មុនដំបូងគេប្រុងឲ្យឡើងធ្វើទ័ព ដល់ទាក់ទិនទៅគេទុកឲ្យចាំមើលសកម្មភាពយើង តាមពិតពីណាដូចពីណាទេចង់តែរស់ សុំតែសុខទោះបីធ្វើការម៉េចក៏ដោយ ស៊ីបាយមិនឆ្អែតក៏ថាឆ្អែតដែរ ដើម្បីរស់ ។

ប៊ុនថន : អញ្ចឹងចាំមើលលោកពូដល់ឆ្នាំប៉ុន្មានបានលោកពូចូល?

ខ្ញុំ : ឆ្នាំ៧៩ហើយប៉ុនបានចូល របៀបទុកម៉ាជំនាន់ដែលយើងអស់ភ្នំពេញហើយចូលលែងគិតសមាសភាពហើយបេះតែបញ្ចូលទៅ តែតាមពិតជំនាន់ពន្ធាំរកតែដកអញ្ចឹងឯងព្រោះយើងវាជាប់សមាសភាព ទាល់តែគេនិយាយថាបើប៉ះតែបងប្អូន បើខ្មាំងៗអស់ម៉ាខ្សែហ្នឹង ។

ប៊ុនថន : បាទ!ហើយបងលោកពូហ្នឹង គាត់ខុសអីវិញលោកពូ?

ខ្ញុំ : តាមពិតរឿងរ៉ាវហ្នឹង បើតាមខ្ញុំដឹងបងប្អូនខ្ញុំនិយាយប្រាប់ តែខ្ញុំមិនបានជាក់ស្តែងបានន័យថាវាមិនបានជួបមានតែបងប្អូនម៉ោ ព្រោះជំនាន់ហ្នឹងបងប្អូនខ្ញុំនៅសហករណ៍ទៅជីកប្រឡាយ ដល់អញ្ចឹងវាមានរឿងរ៉ាវក្នុងភូមិៗហ្នឹងគណៈឃុំគេ ជំនាន់ហ្នឹងគេហៅគណៈឃុំកាលជំនាន់ពន្ធាំនោះ គណៈឃុំហ្នឹង អញ្ចឹងក៏ប៉ះពាល់កូនប្រជាពលរដ្ឋ យើងទៅខូចទៅខិលចាប់កូនគេហ្នឹង ដល់អញ្ចឹងអាអ្នកហ្នឹងវាទប់មិនបាន វាសម្លាប់អាអ្នកធំហើយរត់ទៅចូលស្រុកយួនបាត់ទៅ ដល់អញ្ចឹងបងប្អូនហ្នឹងវាព្រឹត្តិការណ៍ហ្នឹងក៏ម៉ោលេងផ្ទះ ដល់ម៉ោលេងផ្ទះគេថាជាប់ខ្សែស្រឡាយគេក៏យកទៅវ៉ៃចោលបាត់ទៅ តាមពិម៉ោពីជីកប្រឡាយសោះ គ្មានទាក់ទិនអីអារឿងហ្នឹងគ្មានដឹង ទៅជីកប្រឡាយមានតិចណាំដើរមួយថ្ងៃវាស់ល្ងាចនោះ ហើយរឿងរ៉ាវក្នុងភូមិអត់ដឹងទេ ។

ប៊ុនថន : បាទ!ប៉ុនកាលហ្នឹងបងលោកពូនៅ?

ទុំ :	និយាយរួមគាត់ស្គាល់ម៉ាភូមិហ្នឹងជិវវាលហើយហ្នឹង នៅផ្ទះជិនាន់ហ្នឹង ខ្ញុំគេយកទៅធ្វើយុវជនអីគេ ហើយគាត់នៅផ្ទះៗជីកប្រឡាយនៅទំបន់ហ្នឹង គេវៃអញ្ចឹងវាជាប់សម្បត្តិជាតិម៉ង ។

ប៊ុនថន :	អញ្ចឹងលោកពូ ពេលបែក៧៥ភ្លាមហ្នឹងពូនៅភូមិទេ ក៏ឡើងម៉ោតាកែវហើយកាល ហ្នឹង?

ទុំ :	ម៉ោតាកែវចេះតែម៉ោៗ យើងរត់ហើយចេះតែម៉ោទៅ ។

ប៊ុនថន :	ហើយនៅតាកែវហ្នឹងបានគេរៀបចំ លោកពូ?

ទុំ :	បាទ!

ប៊ុនថន :	កាលហ្នឹងគេរើសបញ្ចូលយ៉ាងម៉េចដែរលោកពូ យុវជនអីដូចលោកពូអញ្ចឹង?

ទុំ :	ជិនាន់ហ្នឹងឧទាហរណ៍ថាឲ្យតែដល់អាយុ គេប្រមូលរៀបចំជាអង្គភាពដូចនេះអញ្ចឹងយើងរៀបចំជាក្រុមអីនេះទៅ តាមភូមិតាមក្រុម ម៉ាផ្នែកនៅតាមភូមិ ម៉ាផ្នែកនៅឃុំអញ្ចឹងទៅ ជាប់ជាមួយភូមិជាមួយឃុំគេពីដើមអាហ្នឹង ។

ប៊ុនថន :	បាទ!

ទុំ :	បាទ!យុវជនភូមិ យុវជនឃុំគេនៅហ្នឹង ។

ប៊ុនថន :	ហើយពូម៉ោនៅម្តុំណាវិញលោកពូ ពេលរត់ហើយ?

ទុំ :	ពេលម៉ោនេះខាងត្បូងតាកែវជិតភ្នំមីមៀលនេះ ។

ប៊ុនថន :	ដីរមៀលនៅម៉ាជួរជិតស្រុកត្រាំកក់នេះ?

ទុំ :	បាទ!គេយកផ្ទះប្រមូលម៉ោកងយុវជនគេហ្នឹង កងៗគេម៉ោដាក់ហ្នឹង ម៉ាកងៗឧទាហរណ៍ថាត្រូវការគេវៃបែក តាំងពីជិនាន់លន់ ណុលហឹងគេវៃបែកកន្លែងណា គេយកកម្លាំងយុវជនទៅជួយដឹកជញ្ជូនគ្រាប់ ជញ្ជូនអីចេញពីបន្ទាយទីតាំងហើយ និយាយរួមដូចយើងនៅនេះឧទាហរណ៍ថាដូចស្នាក់ការគេ អញ្ចឹងឧទាហរណ៍ត្រូវការយកជញ្ជូនគ្រាប់ជញ្ជូនទៅ ចុះជិនាន់លន់ ណុលគេវៃបែកគ្រាប់រំសេវមិននៅពេញហ្នឹង អញ្ចឹងគេត្រូវការជញ្ជូនចេញពីទីតាំងយន្តហោះទម្លាកលអីហ្នឹង អញ្ចឹងគេយកចេញពីហឹង ។

ប៊ុនថន :	កាលហ្នឹងអ្នកគ្រប់គ្រងរួមពីណាវិញ លោកពូ?

ទុំ :	ខ្ញុំភ្លាប់អត់បានទេជិនាន់ហ្នឹង យើងដឹងតែថា ដឹងតែត្រឹមប៉ុន្នាន ធ្វើបានត្រឹមហ្នឹងទៅយើងសួរដេញដោលគេថាយើងស្រាវជ្រាវ និយាយខ្វីថា យើងទាំងអស់គ្នាសុំតែម៉ា រស់ ។

ប៊ុនថន :	បាទ!នៅដល់ពេលនេះហើយបានពូម៉ោនៅណាវិញទៀតពូ?

ទុំ : ដល់ពេលម៉ោបានម៉ោឆ្ងាយដល់នេះម៉ោ ៧៩ចេះតែរត់ៗម៉ោគេឯងទៅ កាលហ្នឹងគេកែនគេកៀរម៉ោចេះតែម៉ោៗគេទៅ ហើយក៏ឆ្ងាយដល់អស់ហ្នឹងៗក៏ម៉ោហ្នឹងរហូតទៅ ។

ប៊ុនថន : ប៉ុន៧៩ ហើយហ្នឹងពូចេញពីដីរមៀលទៅនៅទៀតលោកពូ?

ទុំ : ចេញពីមីមៀលខ្ញុំម៉ោនៅនេះ ទៅស្រុកកោះអណ្ដែតវិញ ស្រុកកំណើតនោះវិញ ។

ប៊ុនថន : ពូទៅហ្នឹងនៅរយៈពេលប៉ុន្មានឆ្នាំ ពូទៅស្រុកកំណើតហ្នឹង?

ទុំ : ទៅស្រុកកំណើតតាមពិតអត់ទៅដល់ហ្នឹងទេ ខ្ញុំតែមាដ្ឋរបាក់ដៃ អត់ដែលទៅដល់ស្រុកនៅផ្ទះផង ។

ប៊ុនថន : បាទ! បាក់ដៃហ្នឹងនៅស្រុកណាវិញ?

ទុំ : អាហ្នឹងនៅស្រុកកោះអណ្ដែតដែរ វាជាប់ជាមួយយួនព្រំដែន ។

ប៊ុនថន : នៅហ្នឹងពូធ្វើអីដែរ ប្រចាំការណ៍ឬមួយ?

ទុំ : កាលហ្នឹងខ្ញុំធ្វើកងទ័ពដែរ គេឲ្យធ្វើកងទ័ព ប៉ុននៅការពារព្រំដែនគេហ្នឹងទឹក ។

ប៊ុនថន : ខាងទឹកវិញពូ?

ទុំ : បាទ! ចុះស្រុកខ្ញុំតែខែវស្សាឡើង សុទ្ធតែទឹកហើយ គោកតែខែប្រាំង ។

ប៊ុនថន : បាទ! ហើយនៅហ្នឹងទឹកច្រើនទេលោកពូ?

ទុំ : ទឹកច្រើន យើងទឹកសមុទ្រវាជោរនាជទៅខែហ្នឹង ។

ប៊ុនថន : អញ្ចឹងមិនមែនពូនៅផ្នែកដើងទឹកទេ?

ទុំ : អត់ទេៗ! របៀបឧទាហរណ៍ថានៅព្រំដែន ក្នុងនាមតំបន់វាលិចទឹក ខែវស្សាវាលិចទឹក ខែប្រាំងវាអត់ទឹកអញ្ចឹង អត់ដែលដើងទឹកដើងអីអត់ដែលទេ ។

ប៊ុនថន : កាលហ្នឹងគេបែកពូនៅកងវរៈប៉ុន្មានពូកាលហ្នឹង?

ទុំ : វរៈប៉ុន្មានទេ ដូចពីរ៧០ ។

ប៊ុនថន : នៅជាមួយពីណាកាលហ្នឹងប្រធានវរៈ?

ទុំ : កាលហ្នឹងប្រធានវរៈស្លាប់បាត់ហើយ ។

ប៊ុនថន : ដល់ពេលក្រោយម៉ោឡើងពីណាវិញពូ?

ទុំ : ដល់ក្រោយមកទៀតនិយាយពី៧៩ ខ្ញុំម៉ោនេះហ្នឹង ។

ប៊ុនថន : ប៉ុនដឹងតែកងពលប្រធានឈ្មោះ វ៉ែន?

ទុំ : បាទ! ឈ្មោះ វ៉ែន ។

ប៊ុនថន : ចុះពីលើគាត់ទៀតមានអ្នកលើទៀតទេ?

ខ្ញុំ : លើទៀតតា ប៊ិត យើងនិយាយមិញ ។

ប៊ុនថន : អញ្ចឹងពូនៅហ្នឹងនៅប្រចាំការណ៍ ក៏យើងទៅនៅរបៀបម៉េចវិញលោកពូ?

ខ្ញុំ : យើងរស់នៅតាមព្រំដែនខទាហរណ៍ថា ទៅប្រចាំការណ៍ការពារនៅព្រំដែនអញ្ចឹង ខទាហរណ៍នៅថាយើងនៅនោះអញ្ចឹង ការពារនៅព្រំដែនថៃនៅប្រចាំការបោះទីតាំងនៅការពារកន្លែងបោះព្រំដែនៗខាងត្បូង ។

ប៊ុនថន : សុទ្ធតែទ័ពទាំងអស់?

ខ្ញុំ : បាទ!សុទ្ធតែទ័ព ប៉ុនទ័ពថាទ័ព ធ្វើតែស្រែដែរ ។

ប៊ុនថន : ចុះដូចថាអ្នកតាមព្រំដែនហ្នឹងមានអ្នកឆ្លងទៅម៉ោឬអត់ពូ?

ខ្ញុំ : អត់ទេ!អត់មានឆ្លង ជំនាន់ហ្នឹងអត់មានឆ្លងទេ ខទាហរណ៍ថាបើគណៈគ្រប់គ្រងឬក៏ទាហានវៀតណាមអីម៉ោជួបគ្នា ម៉ោជួបកន្លែងហ្នឹង ហើយឆ្លងចុះឆ្លងឡើងដើរលេងចុះឡើងអត់ទេ ព្រំដែនហ្នឹងខទាហរណ៍ថាបើត្រូវការមានបញ្ហាឈ្លោះព្រំដែននិយាយគ្នារឿងនេះអាហ្នឹងជួយគ្នាទៅ ។

ប៊ុនថន : អញ្ចឹងមានជួយគ្នាដែលលោកពូ?

ខ្ញុំ : បាទ!ខទាហរណ៍យើងការពារព្រំដែននោះ ដូចវៀតណាមការពារខាងដីគេ យើងការពារខាងដីយើងមានចេញចូលអីហ្នឹង យើងរាយការណ៍ទៅដោះស្រាយទៅ ។

ប៊ុនថន : បាទ!ចុះខាងទំនាក់ទំនងអីគេផ្នែកផ្សេងទៀត?

ខ្ញុំ : អាហ្នឹងផ្សេង បើយើងនិយាយឥឡូវគេថាផ្លូវរដ្ឋាភិបាល តួនាទីអញ្ចឹងទេ ខទាហរណ៍ថាគ្រាន់តែសម្រួលគ្នា ខទាហរណ៍ថាបើប្រជាជនចូលម៉ោដីយើង យើងទៅប្រាប់គេ បើប្រជាជនយើងចូលទៅដីគេ គេម៉ោប្រាប់យើងតែប៉ុនហ្នឹង អារឿងការងារអីខាងនេះអត់ដឹងទេ មានតួនាទីតែប៉ុនហ្នឹងអ្នកព្រំដែន ។

ប៊ុនថន : បាទ!

ខ្ញុំ : ប៉ុនព្រំដែនថាព្រំដែនទេ ជំនាន់ហ្នឹង ខទាហរណ៍ថា១ខែទៅ ១ខែម៉ោជីកតែប្រឡាយលើកទំនប់ដូចតែគ្នាហ្នឹង ។

ប៊ុនថន : អញ្ចឹងកាលធ្វើទ័ព យើងជួយជីកប្រឡាយជីកអីដែរ?

ខ្ញុំ : បាទ! ជីកប្រឡាយតាមជួរព្រំដែន ជីកប្រឡាយអញ្ចឹងទៅធ្វើស្រែប្រាំងធ្វើអីទៅ ប៉ុនតែធ្វើស្រែប្រាំងនោះអត់មានប្រជាពលរដ្ឋទេ មានតែកម្លាំងទ័ពទេ ទ័ពខទាហរណ៍ថាអ្នកខ្លះទៅប្រចាំការណ៍ទៅប្រចាំទៅ អាអ្នកនៅធ្វើស្រែ ។

ប៊ុនថន : បាទ!អញ្ចឹងពូតែកងទ័ពទេ មេក្រុមមេអីនោះ មានបានឡើងតួនាទីទេពូ?

ខ្ញុំ : អត់ទេជំនាន់ហ្នឹង ដូចខ្ញុំជំរាបខាងដើមថាវាជាប់សមាសភាព តែទឹមម៉ារស់ៗគេតាមដានប្រើកល្បចទៀតនោះ គ្មានអ្នកណាគេទុកចិត្តឲ្យយើងធ្វើព្រោះកាលណាតែធ្វើមេ យើងដឹងរឿងផ្ទៃក្នុងរបស់គេ យើងដឹងថាទឹមម៉ារស់ប៉ុនហ្នឹងបាន ។

ប៊ុនថន : កាលហ្នឹងពូ កាលពេលហ្នឹងមានដូចថាមានបញ្ហាជាមួយខាងវៀតណាម បញ្ហាខាងព្រំដែនអីអញ្ចឹង កាលហ្នឹងពូទៅប្រចាំការណ៍ឬនៅពូ?

ខ្ញុំ : កាលហ្នឹងខ្ញុំនៅប្រចាំការណ៍ វាដូរឲ្យខ្ញុំម៉ោក្រោយវិញ មកជួយធ្វើស្រែតាមសហករណ៍នេះ ។

ប៊ុនថន : បាទ!ពូទៅប្រចាំការណ៍បានប៉ុន្មានបានដូរ?

ខ្ញុំ : ប្រចាំការណ៍ជំនាន់ពេលហ្នឹងគេឲ្យ ជួនកាលអាកងវរៈខ្លះដាច់មុខ គេឲ្យនៅចាំដាច់មុខទៅ អ្នកក្រោយដើរធ្វើស្រែទាំងអស់ហ្នឹង ហើយខ្ញុំប៉ះពាល់រឿងធ្វើព្រំដែនហ្នឹងខ្ញុំម៉ោមុខ គេដកឲ្យម៉ោជួយធ្វើស្រែទៅ ។

ប៊ុនថន : ចុះពូមានដឹង ដូចថាមានបញ្ហាជាមួយខាងវៀណាម មានវ៉ៃគ្នាមានអីទេ កាលមាន ជម្លោះនៅឆ្នាំ៧៧ហ្នឹងមានជម្លោះព្រំដែនជាមួយគ្នាអី?

ខ្ញុំ : បាទ!ជំនាន់ហ្នឹងខ្ញុំគ្រាន់តែដឹង ដូចខ្ញុំជម្លៀសម៉ោនៅឆ្ងាយ ដកពីព្រំដែន គ្រាន់តែដឹងថាមុនដំបូងវៀតណាមវ៉ៃចូល ចូលដីយើងចូលដីខ្មែរហ្នឹង ដល់ក្រោយម៉ោគេលើកដែនការណ៍គេវ៉ៃបកវ៉ៃអីលិចកើតអញ្ចឹងទៅ ប៉ុនខ្ញុំដាច់ពីព្រំដែនហើយកាលហ្នឹង ។

ប៊ុនថន : កាលហ្នឹងពូម៉ោណាវិញ គេបញ្ជូនម៉ោណា?

ខ្ញុំ : គេបញ្ជូនម៉ោធ្វើស្រែនេះ នៅជិតកំពង់ស្ពឺ ធ្វើស្រែនៅម៉ាដួរគោកែវហ្នឹង ។

ប៊ុនថន : ដកច្រើនទេពូ ដកចេញហ្នឹង?

ខ្ញុំ : ដក ឧទាហរណ៍ថាដូចខ្ញុំជំរាបខាងដើមឥឡូវថា បើយើងប្រវត្តិមិនសូវស្អាត អាហ្នឹងគេដកចេញម៉ោភ្លាម ។

ប៊ុនថន : បាទ!អញ្ចឹងពេលជម្លោះនឹងពូគេដកចេញម៉ោក្រៅ?

ខ្ញុំ : បាទ!

ប៊ុនថន : ពូម៉ោនៅខាងស្ពឺនេះនៅខាងស្រុកណាវិញពូ?

ខ្ញុំ : ម៉ោខាងកំពង់ស្ពឺម៉ោស្រុកគងពិសី ។

ប៊ុនថន : កាលហ្នឹងស្រុកគងពិសី តំបន់ប៉ុន្មានពូ?

ខ្ញុំ : តំបន់៣៣អាហ្នឹង ។

ប៊ុនថន : ៣៣កាលហ្នឹងពីណាអ្នកគ្រប់គ្រងពូ?

ខ្ញុំ : ខ្ញុំអត់ស្គាល់ដែលហ្នឹង មិនដឹងពីណាទេ ។

ប៊ុនថន : បាទ!ហើយលោកពូនៅខាងកងពិសីនេះរហូត ឬក៏មានផ្លាស់ទៅកន្លែងផ្សេងទៀត?

ខ្ញុំ : អត់ទេ!នៅកន្លែងកងពិសីរហូតតែប៉ុនហ្នឹងទល់៧៩ហើយ ។

ប៊ុនថន : ឆ្នាំ៧៩បានពូចូលមកម្តងទៀត?

ខ្ញុំ : ឆ្នាំ៧៩នៅពេលដែលគេកៀរម៉ោ ចេះតែម៉ោៗគេទៅ ចេះតែបោលតាមគ្នាហ្នឹង ។

ប៊ុនថន : ម៉ោណាទៅលោកណូងបូង?

ខ្ញុំ : រត់ម៉ោកំពង់ស្ពឺខាងជើងថ្នល់លេខ៤ម៉ោ ចេះតែម៉ោៗក៏ធ្លាយដល់ហ្នឹងទៅ ។

ប៊ុនថន : បាទ!កាលហ្នឹងមានអ្នកដឹកនាំម៉ោដែរលោកពូ ?

ខ្ញុំ : កាលហ្នឹងចេះតែរគាត់រគាយចេះតែរត់តាមគ្នាទៅណា៎ ចេះតែខ្វាចវៀតណាមលិចកើត ចេះតែបបួលគ្នារត់ទៅ នៅជិតនាំ៣ឆ្នាំ ខ្លាចគេយកវៃចោលអស់ចេះតែរត់ទៅ ចេះតែភ័យ យកម៉ារស់រៀងៗខ្លួនទៅ ។

ប៊ុនថន : បាទ!អញ្ចឹងម៉ោដល់ណាវិញពូកាល៧៩ហ្នឹង?

ខ្ញុំ : នៅខាងព្រំដែនខាងបាត់ដំបងនោះ ។

ប៊ុនថន : នៅខាងបាត់ដំបង?

ខ្ញុំ : បាទ!

ប៊ុនថន : ទៅដល់នោះគេមានប្រមូលផ្តុំឡើងវិញទេពូ?

ខ្ញុំ : គេប្រមូលផ្តុំ ឧទាហរណ៍ថាទ័ពគេប្រមូលហើយ អាខ្លះគេធ្វើអាខ្លះអត់អញ្ចឹងទៅ ។

ប៊ុនថន : កាលហ្នឹងពូចូលជាមួយ វ៉ែន ហ្នឹងវិញពូ?

ខ្ញុំ : បាទ!ដាច់គ្នាហើយ ខ្ញុំលែងនៅហើយ ខ្ញុំម៉ោនៅជាមួយ កែវ ពង្ស នេះវិញ ។

ប៊ុនថន : បាទៗ!ខ្ញុំធ្លាប់ឮឈ្មោះគាត់ដែរ កែវ ពង្ស កាលហ្នឹងគាត់នៅខាងកងពលលេខប៉ុន្មាន កែវ ពង្ស?

ខ្ញុំ : កងពល១៨ ខាងកំពង់ស្ពឺ នៅជិតនាំពី៧០ទៅ៧៥គេរំដោះហើយ នៅម៉ាឈឺមអញ្ចឹង ទៅម្តងនៅនេះម្តងនៅនោះអញ្ចឹងទៅ ក្រោយម៉ោខ្ញុំនៅជាប់ជាមួយ កែវ ពង្សហ្នឹង ។

ប៊ុនថន : បាទ!ពូនៅបាត់ដំបងហ្នឹងនៅម្តុំណាពូ?

ខ្ញុំ : នៅស្រុកសំឡូតហ្នឹង ។

ប៊ុនថន ៖ នៅសំឡូត?

ខ្ញុំ ៖ បាទ!

ប៊ុនថន ៖ អញ្ចឹងម៉ាតំបន់សំឡូតហ្នឹងគាត់ជាអ្នកគ្រប់គ្រង កែវ ពង្ស ហ្នឹង?

ខ្ញុំ ៖ កែវ ពង្ស អត់ទេ គ្រាន់តែឆ្លងកាត់ទេ ការពិតតំបន់ហ្នឹងជាតំបន់រំដោះជំនាន់ខ្មែរក្រហមនោះណា អញ្ចឹងអ្នកពីមុខទៅ កំពង់ស្ពឺអីចូលទៅ ចូលទៅហ្នឹងម៉ង ទៅធ្វើការធ្វើអីគេហៅហ្នឹង ។

ប៊ុនថន ៖ បាទ!

ខ្ញុំ ៖ ប៉ុនដល់ហើយចេញមកវិញទេ តាមពិតមិនមែនអចិន្ត្រៃយ៍ទេ ឆ្លងកាត់ទៅ កែវ ពង្ស គាត់នៅប្រចាំការនៅកំពង់ស្ពឺនេះទេ អញ្ចឹងខ្ញុំនៅជាមួយគ្រាន់តែជាកម្លាំងជួយដឹកជញ្ជូនគ្រាប់ហ្នឹងទេ ឲ្យដឹកឲ្យគេហ្នឹងហើយ ។

ប៊ុនថន ៖ អញ្ចឹងពូនៅកំពង់ស្ពឺជាមួយគាត់ហើយបានម៉ោសំឡូតនេះ?

ខ្ញុំ ៖ បាទ!ម៉ោសំឡូតហ្នឹង ដល់ជាប់យើងនេះទៅ បានចូលកំពង់ស្ពឺ ដូចខ្ញុំបានជំរាបហើយបានជួបជាមួយ កែវ ពង្ស យើងម៉ោនេះម៉ោអញ្ចឹងទៅ ដល់ក្រោយម៉ោបានគាត់ទៅធ្វើការហ្នឹងទៀតទៅ ។

ប៊ុនថន ៖ សព្វថ្ងៃគាត់នៅណាវិញ កែវ ពង្ស?

ខ្ញុំ ៖ នៅជាមួយរដ្ឋាភិបាល ។

ប៊ុនថន ៖ បាទ!គាត់នៅខាងភូមិភាគណាវិញសព្វថ្ងៃ?

ខ្ញុំ ៖ អត់ទេ!គាត់នៅផ្កាយបី នៅខាងរង ។

ប៊ុនថន ៖ គាត់នៅស្គាល់ពូទេសព្វថ្ងៃ?

ខ្ញុំ ៖ ស្គាល់ ចុះអបើធ្លាប់នេះជាមួយគ្នា កំសត់កំរជាមួយគ្នាបេះតែស្គាត់រកគ្នាទៅ ។

ប៊ុនថន ៖ អ៊ូ!អត់ដែលជួបពូទេ?

ខ្ញុំ ៖ ជួប កាលមុនម៉ោព្រំដែនគាត់ចូលលេង ។

ប៊ុនថន ៖ ចូលលេងផ្ទះពូ?

ខ្ញុំ ៖ បាទ!

ប៊ុនថន ៖ បាទ!អញ្ចឹងពូបាត់មួយរយៈបានទៅខាងសំឡូត ហើយខាងសំឡូតពីណាអ្នកគ្រប់គ្រងបានទៅខាងសំឡូតវិញពូ?

ខ្ញុំ : គ្រប់គ្រងហ្នឹង កែវ ពង្សដដែលហ្នឹងឧទាហរណ៍ថា គាត់ទៅសមរភូមិសំឡូត ប៉ុនកន្លែងហ្នឹងកម្លាំងហ្នឹងនៅតែសំឡូតហ្នឹង ត្រូវការទៅកំពង់ស្ពឺអីកម្លាំងហ្នឹង ម៉ោកំពង់ស្ពឺសម្រាកហ្នឹងហើយ ហើយទៅកំពង់ស្ពឺហ្នឹងទៅ ស្នាក់នៅចេញចូល អចិន្ត្រៃយ ប្រចាំការធ្វើការហ្នឹងអត់ទេអីអត់ទេ ប៉ុនមានភារៈកិច្ចថាយើងទៅធ្វើការខ្លះប៉ុនសម្រាកគេ ហើយយើងចេញចូលហ្នឹង គេត្រូវការហៅក៏ម៉ោ គេមិនត្រូវការក៏ហីទៅ ។

ប៉ុនថន : ចុះខាង មាស មុត ខាង ស៊ូ ម៉េតអីគាត់អត់គ្រប់គ្រងនៅហ្នឹងទេ នៅសំឡូតទេ?

ខ្ញុំ : ខាង មាស មុត ខ្ញុំក្តាប់អត់សូវបានព្រោះគាត់កាលមុនទៅនៅអន្លង់វែង ហើយឈ្មោះម៉េតឈ្មោះអីខ្ញុំក្តាប់មិនសូវបានដែរ ម្យ៉ាងជំនាន់នោះអត់នៅជាមួយគ្នាផង យើងឧទាហរណ៍ថានៅជាមួយគ្នាស្គាល់តែអ្នកនៅជាមួយគ្នាហ្នឹងទៅ ។

ប៉ុនថន : អញ្ចឹងគាត់មិនមែនខាងសំឡូតជាមួយលោកពូទេ ផ្សេងគ្នា?

ខ្ញុំ : អត់ទេខ្ញុំអត់ទាក់ទិនខាងសំឡូតហ្នឹងទេ ដូចខ្ញុំជំរាបថាគ្រាន់តែជាកន្លែងនៅហ្នឹង ។

ប៉ុនថន : បាទ!គ្រាន់តែស្នាក់នៅជាបណ្តោះអាសន្នទេ?

ខ្ញុំ : បាទ!គាត់នៅជាប់ជាមួយ កែវ ពង្ស ចេញចូលៗមួយដងម្កាល់ទេ បើនៅប្រចាំការសមរភូមិនៅធ្វើអីហ្នឹងគឺអត់ទេ ។

ប៉ុនថន : ពូនៅជាមួយគាត់ផ្ទាល់ នៅជាមួយកែវ ពង្សផ្ទាល់?

ខ្ញុំ : អត់ទេ!នេះគ្រាន់តែជាអង្គភាព ហើយដូចខ្ញុំអ្នកយកគ្រាប់រំសេវអីហ្នឹង ដលល់ម៉ោភូមិជំនាន់យើង៧៩ហើយនេះណា៎ បើថាអានៅផ្ទាល់អត់ទេ ខ្ញុំអ្នករៀបចំមើលកម្លាំងអ្នកដឹកជញ្ជូនយកគ្រាប់ទៅសមរភូមិតែប៉ុនហ្នឹងទេ ។

ប៉ុនថន : បាទ!

ខ្ញុំ : ហើយសមរភូមិកំពង់ស្ពឺនោះទេ សំឡូតនេះគ្រាន់តែកន្លែងស្នាក់ ឬតំបន់ខ្មែរក្រហមមួយហ្នឹង ។

ប៉ុនថន : កំពង់ស្ពឺនៅណា ភ្នំឱរ៉ាល់ហ្នឹងពូ?

ខ្ញុំ : បាទ!ភ្នំឱរ៉ាល់ហ្នឹងឯង ម្តុំត្រពាំងជោរ ត្រពាំងអីហ្នឹង អមលាំងអីហ្នឹង ។

ប៉ុនថន : បាទ!ហ្នឹងម៉ាដួរពូ?

ខ្ញុំ : កាលហ្នឹង កែវ ពង្ស ហើយម៉ោក្រោយសមាហរណកម្មម៉ោ កែវ ពង្ស នាំកម្លាំងទៅខាងក្នុងអស់ទៅ ។

ប៉ុនថន : បាទ!

ខ្ញុំ :	ទៅជាមួយរដ្ឋាភិបាល ។

ប៊ុនថន :	អញ្ចឹងពូដូចថាមានទំនាក់ទំនងផ្សេងៗនេះទេ ដូចថាតំបន់ផ្សេងៗនៅតំបន់ឱរ៉ាល់ហ្នឹង ដូចថាទំនាក់ទៅប៉ៃលិន ទៅសំឡូតទៅអីនោះ?

ខ្ញុំ :	អាហ្នឹងអត់ទេ សំខាន់តាមរយៈមេៗគេទេ យើងឧទាហរណ៍ថា មានតួនាទីម៉េង គេឲ្យទៅណាគឺទៅហ្នឹង យើងនៅក្រោមគេចេះតែស្ដាប់បង្គាប់គេទៅ ។

ប៊ុនថន :	តែម៉ាតំបន់រ៉ាល់ហ្នឹងទេ?

ខ្ញុំ :	បាទ!

ប៊ុនថន :	តំបន់ផ្សេងគេ?

ខ្ញុំ :	តំបន់ផ្សេងគេអ្នកផ្សេងទៀតទេ យើងអត់មានទៅទាក់ទិនអីគេ ។

ប៊ុនថន :	បាទ!ប៉ុន្តែមានប្រជុំមានអីទេពូ ដូចថាប្រជុំរួមប្រជុំអី?

ខ្ញុំ :	បាទ!ប្រជុំមានតែមេៗធំៗគេទេ មេៗឧទាហរណ៍ដូចថាគេរៀបចំតែថ្នាក់មរភូមិ ថ្នាក់អីគេហៅទៅប្រជុំហើយហ្នឹងសម្រាប់ធំៗហើយ សម្រាប់យើងមេម៉ោដល់ គេថាហ៎!ឥឡូវកម្លាំងជួយជញ្ជូនគ្រាប់ដាក់នេះនោះតែប៉ុនហ្នឹងទេ ហើយបើថាអាការងារអីយើងអត់ដឹងទេ ។

ប៊ុនថន :	បាទ!ប្រជុំហ្នឹងគេប្រជុំនៅណា នៅតាមតំបន់រៀៗខ្លួន ឬក៏មោប្រជុំនៅ?

ខ្ញុំ :	អាហ្នឹងគេហៅប្រជុំស្រេចតែគេហៅ ខ្ញុំអត់ដែលនេះផង ឧទាហរណ៍ថាកន្លះឆ្នាំមួយឆ្នាំ គេហៅមេៗប្រជុំមួយដង ដល់គេម៉ោប្រជុំម៉ោ គេថាឥឡូវជួយជញ្ជូនគ្រាប់ទៅនេះ ទៅយកគ្រាប់ខគេអញ្ចឹងទៅ ។

ប៊ុនថន :	បាទ!កាលហ្នឹងពូនៅខាងតំបន់ឱរ៉ាល់ហ្នឹងមានតំបន់ណាខ្លះពូ ពូណាទៅណា?

ខ្ញុំ :	កាលហ្នឹងដូចអត់មានតំបន់អីទៀតទេ អស់ពី៧៩ម៉ោអត់មានតំបន់ទៀតទេ ។

ប៊ុនថន :	បាទ!ហើយបែងចែក?

ខ្ញុំ :	ឧទាហរណ៍ថាធ្វើការក្នុងខេត្តនេះ កងនេះធ្វើការខេត្តនេះ កងនោះធ្វើការខេត្តនោះ អញ្ចឹងគេអត់មានចែកតំបន់គ្នាទៀតទេ ។

ប៊ុនថន :	ប៉ុនពីកន្លែងពូហ្នឹងពីណាដល់ណា តាមកំពង់ស្ពឺតែមូលទេពូ?

ខ្ញុំ :	បាទ!តែមួយទេ ។

ប៊ុនថន :	អាហ្នឹងកាត់ទៅដល់?

ខ្ញុំ :	កាត់ទៅដល់កំពតដល់អីអាហ្នឹងអ្នកផ្សេងទៀតទេ ។

ប៊ុនថន : ពូនៅជាមួយគាត់ដល់ឆ្នាំណា នៅជាមួយកែវ ពន្សូ?

ទុំ : នៅទល់យើងសមាហរណកម្មហ្នឹង ៧៩រហូតដល់យើងសមាហរណកម្មហ្នឹង ៧៩ម៉ោ យើងជួបគ្នាៗនៅជាមួយគ្នារហូតទៅហ្នឹងទៅ កម្លាំងអ្នកដឹកជញ្ជូនឲ្យគេទៅ ។

ប៊ុនថន : បាទ!ដឹកជញ្ជូន អញ្ចឹងដឹកជញ្ជូនហ្នឹងដូចភស្តុភាហ្នឹងពូ?

ទុំ : ភស្តុភាវាមានមេគេមួយទៀត បើនិយាយទៅរៀបចំជាមេក្រុមអី គ្រាន់តែកម្លាំងជួយប្រមូលកម្លាំងទៅណ៎ា ខាងផ្នែកគេមានភស្តុភាៗសម្រាប់សមរភូមិគេផ្សេងទៀត ។

ប៊ុនថន : កាលហ្នឹង កែវ ពន្សូ គាត់មានតួនាទីតែខាងប្រធានកងពល១៨ហ្នឹងទេ?

ទុំ : បាទ!ខាងទ័ពដែរ ។

ប៊ុនថន : បាទ!កាលហ្នឹងស្នាក់ការគេធំម៉ងនៅណាវិញពូ?

ទុំ : នៅខាងស្រុកសំឡូតហ្នឹង ស្នាក់ការ សំឡូតហ្នឹងនៅជាប់ព្រំដែនថៃ កាលហ្នឹងទីតាំងខ្មែរក្រហមនៅសំឡូតជាប់នឹងថៃហ្នឹង រឿងមេៗទៅប្រជុំភាគច្រើនគេថាទៅថៃ ។

ប៊ុនថន : អញ្ចឹងពូដឹកពីនេះទៅ?

ទុំ : បាទ!ដឹកពីនេះយកទៅ ។

ប៊ុនថន : ពេលពូដឹកយកទៅរយៈពេលប៉ុន្មាន?

ទុំ : ជិត២ខែនោះ ។

ប៊ុនថន : ដឹកចេញពីសំឡូត កាត់តាមផ្លូវណាខ្លះពូ?

ទុំ : ផ្លូវតាមផ្លូវជាតិលេខ៨ អាណាខ្លះក៏ឆ្លងផ្លូវជាតិលេខ៨ទៀត ខ្លះក៏ត្រឹមផ្លូវជាតិលេខ៨ ជួនកាលមានមួយខែពីរខែនោះ ។

ប៊ុនថន : ទាក់ទងគ្នាតាមតេអូ តាមតេឡេក្រាមអីទៅ?

ទុំ : អត់ទេ!កាលហ្នឹងគេប្រើទូរលេខ ។

ប៊ុនថន : អញ្ចឹងពូទៅជុំគ្នា នៅសំឡូតហ្នឹង?

ទុំ : បាទ!នៅជុំគ្នាទៅ មេៗគេទៅធ្វើការអស់ កំពុងប្រជុំៗគេថាហ៎ទៅទៀត ក៏ទៅទៀតទៅទៅម៉ោៗ ។

ប៊ុនថន : ចុះខាងសំឡូតហ្នឹងមានដឹកជញ្ជូនតែម៉ោខាងឧិវ៉ាល់ មានដឹកទៅកន្លែងផ្នែកផ្សេងៗទៀតទេពូ?

ទុំ : អាហ្នឹងវាតាមសមរភូមិវា ។

ប៊ុនថន : ទៅសមរភូមិណាខ្លះពូ?

ខ្ញុំ : បាទ! ឧទាហរណ៍ថាខ្លះ គេដឹកជញ្ជូនម៉ោខាងបាត់ដំបងអញ្ចឹងម៉ោ ខ្លះទៀតទៅខាងប៉ៃលិនអញ្ចឹងទៅ យើងក្រុមមានផ្នែកៗគេអញ្ចឹងទៅខុសៗគ្នា ឧទាហរណ៍ថាបើអ្នកណាប្រចាំការម៉ោភូមិហ្នឹង ត្រូវម៉ោភូមិហ្នឹងទៅ យើងប្រចាំណាត្រូវម៉ោភូមិហ្នឹងទៅ ។

ប៊ុនថន : ដឹកចេញពីដីថៃឬយកពីខ្មែរទៅ?

ខ្ញុំ : មុនដំបូងគេច្រើនយកមកពីដីថៃ ក្រោយម៉ោដឹកយកមកពីដីខ្មែរ ពេលដែលគេវ៉ៃពីកងទ័ពវៀតណាមដកចូលព្រំដែនហ្នឹង គេឡើងមកកាន់កាប់ដីខ្មែរវិញ ប៉ុនដល់យកៗតាមរយៈថៃវិញ គេដឹកជញ្ជូនម៉ោអញ្ចឹងទៅ ឡានគេដឹកម៉ោលើម៉ោយើងអ្នកជញ្ជូនតទៅទៀតណា៎ ។

ប៊ុនថន : យើងដឹកឡានដែលពូ?

ខ្ញុំ : ស្ពាយនឹងខ្នងនឹង ។

ប៊ុនថន : ស្ពាយនឹងខ្នងយើងហ្នឹង?

ខ្ញុំ : បាទ!ផ្លាស់ប្តូរគ្នាស្ពាយ ។

ប៊ុនថន : មាក្រុមប៉ុន្មាននាក់ក្រុមលោកពូ?

ខ្ញុំ : មាក្រុម១០នាក់ៗគេដឹកដល់ហ្នឹង គេដាក់កាឌុងមួយៗម្នាក់អាឌុងចិននោះ កាលហ្នឹងម្នាក់ៗមានតែអង្ករហូប មានខោអាវស្បៀកពាក់ខ្លួនឯង គ្រាប់រំសេវនៅហ្នឹងទៀត ។

ប៊ុនថន : ចុះពេលដឹកជញ្ជូនហ្នឹងមានកាំភ្លើងមានអីការពារខ្លួនទេ?

ខ្ញុំ : មាន កាំភ្លើងហ្នឹងមិនធម្មតាទេ ដឹកជញ្ជូនហ្នឹងវាឆ្លងកាត់តំបន់ដូចខ្ញុំថាអញ្ចឹង កាលមុន៨៦សុទ្ធតែកងទ័ពវៀតណាមនៅតាមហ្នឹង ដូចនេះឆ្លងត្រូវតែប្រើវាហ្នឹង កាំភ្លើងសម្រាប់ការពារនៅពេលយើងធ្វើដំណើរឆ្លងកាត់ប៉ះវាហ្នឹង បើភាគច្រើនអាហ្នឹងកងទ័ពជាអ្នកជញ្ជូនពេលឆ្លងផ្លូវ ។

ប៊ុនថន : បាទ!

ខ្ញុំ : ឧទាហរណ៍ថាម៉ោនោះមានកងណាគេប្រចាំការទាក់ទងគេជញ្ជូនផ្លូវឲ្យ ជូនកាលគេជួយ ឲ្យផុតផ្លូវយើងទៅៗ ។

ប៊ុនថន : ហើយស្គាល់ដែលលោកពូ ឧទាហរណ៍ថាអត់មានអ្នកនាំមុខអី?

ខ្ញុំ : មានអ្នកគេ ឧទាហរណ៍ថា ម៉ោភូមិណាមានកម្លាំងធ្វើការនៅកន្លែងហ្នឹង នៅតាមផ្លូវ៨៦មានកម្លាំងគេការពារនៅហ្នឹងគេធ្វើការហ្នឹង ហើយយើងត្រូវការឆ្លងកាត់ផ្លូវ ឆ្ងាយៗយើងទាក់ទងគេ គេជូនឆ្លងទៅកន្លែងណាប្រឡោះទីតាំងប្រឡោះទទេអញ្ចឹង យើងឆ្លងទៅ ។

ប៊ុនថន :	ក្រុមដឹកជញ្ជូនរបស់ពូទាំងអស់ប៉ុន្មាននាក់ ពីសំឡូតទៅឱរ៉ាល់?

ខ្ញុំ :	អាហ្នឹងវាកម្លាំងវាជួនកាល១០០ទៅ២០០ ខទាហរណ៍មានអ្នកគ្រុន មានអ្នកឈឺអី អាហ្នឹងឈឺគេសម្រាក់នៅហ្នឹង ជាគេទៅទៀត ហើយកម្លាំងមិនមែនកម្លាំងនេះ យើងផ្លាស់ប្តូរលុះត្រាតែយើងឈឺ បើអត់ឈឺទេម៉ោ ហើយអាហ្នឹងខទាហរណ៍ថាបើទៅៗរហូតជួនកាលៗដល់ពាក់កណ្តាលផ្លូវមានអ្នកឈឺ ត្រឡប់ទៅក្រោយវិញខ្លះ ។

ប៊ុនថន :	បាទ!ហើយកម្លាំងហ្នឹងមានស្រី មានប្រុសលាយគ្នាលោកពូ?

ខ្ញុំ :	បាទ!មានស្រី មានប្រុសខ្លះអញ្ចឹងទៅលាយគ្នាអញ្ចឹងទៅ ។

ប៊ុនថន :	ប៉ុនម៉ោខាងម៉ាឡៃហ្នឹងភាគច្រើនសុទ្ធតែស្រីៗហ្នឹងលោកពូ?

ខ្ញុំ :	បាទ!ដូចខ្ញុំជំរាបខាងដើមម៉ាឡៃវានៅជិតថៃដែរ អញ្ចឹងគេយកចេញពីថៃម៉ោ ហើយសមរភូមិគេក៏ជិត ប៉ុនអានេះ ខេត្តកំពង់ស្ពឺវាត្រូវឆ្លងកាត់ខេត្តពោធិ៍សាត់មួយទៀត បើអញ្ចឹងតំបន់វាឆ្ងាយណាស់ៗដល់នេះស្រីៗទៅអត់រួចទេ ដល់យើងប្រុស ។

ប៊ុនថន :	អញ្ចឹងបានជ្រើសរើសយកប្រុសៗ?

ខ្ញុំ :	បាទ!ប្រុសខ្លះ ស្រីខ្លះ ភាគច្រើនគឺប្រុស ព្រោះផ្លូវឆ្ងាយណាស់ដើររយៈពេល២ខែ នោះហើយបើម៉ាឡៃត្រឹមម៉ាអាទិត្យទៅហើយនឹងម៉ោផ្លូវឆ្ងាយៗណាស់ ធម្មតាកាលជំនាន់វៃគ្នាយើងមិនដើរតាមផ្លូវរាបឯណា យើងដើរឡើងភ្នំកាត់ព្រៃដូចនេះកម្លាំងៗស្រីមិនអាចធន់បានទេ ផ្លូវត្រឡប់ម៉ោម៉ាឡៃហ្នឹងវាជិតដូចនេះវាឆាប់បានត្រឡប់ម៉ោផ្ទះបានស្រីៗ ប៉ុនបើយើងខាងនេះភាគច្រើន ប៉ុនបើកំពតនោះភាគច្រើនប្រុស ។

ប៊ុនថន :	ខាងកំពតប្រុស?

ខ្ញុំ :	បាទ!ចុះឆ្លងផ្លូវជាតិលេខ៤ កាត់ប៉ុន្មានខេត្តហើយ ។

ប៊ុនថន :	ចុះពូធ្លាប់ទៅដល់ម៉ាឡៃដែរ?

ខ្ញុំ :	ម៉ាឡៃខ្ញុំអត់ដែលទៅទេ និយាយរួមដូចខ្ញុំជំរាប បានតែនៅត្រឹមហ្នឹងទេ ត្រឹមតែស្រុកសំឡូតទេ ស្រុកសំឡូតសូម្បីតែសាលាស្រុកសំឡូតក៏ខ្ញុំមិនដែលទៅ អត់ដែលស្គាល់ទេ ខ្ញុំនៅម៉ាជួរខាងនេះៗខាងឃុំកំពង់កំពូលនេះ ជាប់អូរសំរិលអូរនងនេះ ខ្ញុំស្គាល់ខាងនេះខាងជើងអត់ដែលស្គាល់ទេ ។

ប៊ុនថន :	ហើយពូអត់ដែលឡើងវៃទេអញ្ចឹង នៅតែខាងដឹកជញ្ជូនទេ?

ខ្ញុំ :	បាទ!ខាងដឹកជញ្ជូនគេ អ្នកទៅវៃផ្សេង យើងខទាហរណ៍ថាមានតួនាទី ប៉ុនខទាហរណ៍គេឲ្យយើងយកគ្រាប់ដាក់កន្លែងណាយើងយកដាក់ត្រង់ហ្នឹង ហើយយើងត្រឡប់ម៉ោ

វិញសម្រាក់ទៅ ឲ្យមានកម្លាំង គ្រាន់តែគេថាហ៎!ជួយយកគ្រាប់ទៀត ទៅទៀតតែប៉ុនហ្នឹង ។

ប៊ុនថន : បាទ!

ខ្ញុំ : អារឿងអ្នកវ៉ៃផ្សេង ។

ប៊ុនថន : បាទ!ចុះកាល ៩៣ ពូនៅណាវិញពេលបោះឆ្នោតហ្នឹង ។

ខ្ញុំ : ៩៣?

ប៊ុនថន : បាទ!

ខ្ញុំ : ៩៣ខ្ញុំនៅហ្នឹងដែរ ។

ប៊ុនថន : នៅសំឡូតដែរ?

ខ្ញុំ : បាទ!ខ្ញុំចេះពីនោះ ខ្ញុំនៅហ្នឹងម៉ង យើងនៅហ្នឹងយើងយកដីយកធ្លី ប៉ុនយើងសមាហរណកម្មយើងត្រូវគ្នាហើយណាស់ រកដីរកធ្លីនៅម្តុំនេះវិញ ។

ប៊ុនថន : បាទ!ចុះ៩៣អត់ទាន់មានប្រែប្រួលអីទេពូ?

ខ្ញុំ : វាជិតហើយ ជិតត្រូវគ្នាហើយ រំដើបរំដួល។ហើយ ពូនេះនៅធ្វើប៉ូលីសរហូតទៅហើយខ្ញុំរ៉ុត្រែតហើយ ។

ប៊ុនថន : លោកពូនៅនោះទាល់តែសមាហរណ៍កម្មលោកពូ?

ខ្ញុំ : បាទ!សមាហរណកម្មខ្ញុំនៅធ្វើប៉ូលីស ។

ប៊ុនថន : សមាហរណកម្មហ្នឹងពូចូលតាមរយៈពីណាវិញពូ កាលពូចូល?

ខ្ញុំ : ជាមួយ កែវ ពង្សដដែលហ្នឹង កែវ ពង្ស ក្រោយពីនេះ កែវ ពង្ស ចូលក្នុងកម្លាំងដឹកនាំកងអគ្គភាពខ្ញុំ ដែលខ្ញុំដឹកនាំឲ្យហ្នឹង ចូលជាមួយរដ្ឋាភិបាល អញ្ចឹងក្រោយម៉ោទាល់តែមានកិច្ចការចុងក្រោយនេះ កែវ ពង្សម៉ោនៅវិញ ។

ប៊ុនថន : អញ្ចឹង កែវ ពង្ស ចូលម៉ោនៅមុនទេ?

ខ្ញុំ : ចូលមុន ។

ប៊ុនថន : ចូលឆ្នាំប៉ុន្មានគាត់?

ខ្ញុំ : ជិនាន់ចរចារគ្នា ។

ប៊ុនថន : ឆ្នាំ ៩១?

ខ្ញុំ : បាទ!ដល់ចូលទៅ ដល់ពេលនេះក្រោយម៉ោ នៅសល់មាំដុបហ្នឹងរត់ម៉ោនេះមាំកញ្ចប់ ហ្នឹង ។

ប៊ុនថន : នៅសល់ពីណា?

ខ្ញុំ : នៅសល់មាំកាដុបក្រោយនេះ មិនទាន់ចូល នៅដឹកនាំជាមួយកម្លាំងរដ្ឋាភិបាលនេះ ដល់ហើយត្រូវគ្នា ។

ប៊ុនថន : អញ្ចឹងកែវ ពង្សចូលហើយពីណាអ្នកគ្រប់គ្រងជំនួសគាត់វិញដឹកនាំ?

ខ្ញុំ : បាទ?

ប៊ុនថន : កែវ ពង្សចូល៩១ហើយអ្នកណាអ្នកចូលដឹកនាំជំនួសគាត់?

ខ្ញុំ : កែវ ពង្សចូលហើយ ក៏ជំនាន់អាពត ដល់ក្រោយម៉ោមិនដឹងអ្នកណាអ្នកណី ខ្ញុំក៏ចប់ត្រឹមហ្នឹងទៅ ។

ប៊ុនថន : ពូចប់ត្រឹមនេះដែរ?

ខ្ញុំ : បាទ!រំលាយចូលក្នុងខ្ញុំក៏នៅនេះទៅ នៅក្នុងភូមិអី ។

ប៊ុនថន : បាទ!លោកពូនៅហ្នឹង បន្ទាប់ពីកែវ ពង្សចូលហើយ ពូឈប់ធ្វើៗខាង?

ខ្ញុំ : បាទ!ដល់កែវ ពង្សនាំចូលអញ្ចឹងទៅខាងនេះគេលែងសួរទុកចិត្ត ។

ប៊ុនថន : ខាងពូហ្នឹង?

ខ្ញុំ : បាទ!ខាងតំបន់យើងខ្មែរក្រហមហ្នឹង ធម្មតាគេថាតែមេវាទៅកូនវាទៅជាមួយគ្នាហ្នឹង អញ្ចឹងគេបញ្ឈប់ទៅជាមួយគ្នាហ្នឹង នៅជំរុំនឹងគេឯងហ្នឹងទៅ ។

ប៊ុនថន : ពូបានទៅនៅជំរុំដែរ?

ខ្ញុំ : ជំរុំយើងនេះអូរល្ហុងនៅជិតព្រំប្រទល់នេះ កែវ ពង្ស ឲ្យទៅហ្នឹងកម្លាំងខ្មែរក្រហមចូលទៅដីថៃហើយ អញ្ចឹងកែវ ពង្សអ្នកដឹកនាំកម្លាំងកងទ័ពនៅពីមុខហ្នឹងចូលទៅអស់ទៅខាងខ្ញុំក៏គេបញ្ចប់ការងារដែរ យើងនៅក្នុងក្រុមជាមួយគេ ចូលរដ្ឋាជាមួយគេឯងទៅ ណា៎ ។

ប៊ុនថន : បាទ!ហើយឆ្នាំប៉ុន្មានបានពូចុះចូលជាមួយរដ្ឋាភិបាល?

ខ្ញុំ : ដូចខ្ញុំជំរាបខាងក្រោយ ដែលយើងសមាហរណកម្មចុងក្រោយបន្តិច ។

ប៊ុនថន : បាទ!លោកពូចូលសមាហរណកម្មហ្នឹងតាមរយៈពីណាវិញលោកពូ?

ខ្ញុំ : តាមរយៈ កែវ ពង្សហ្នឹង ។

ប៊ុនថន : បាទ!កាលហ្នឹងឆ្នាំប៉ុន្មានលោកពូ?

ខ្ញុំ : សមាហរណកម្មហ្នឹងមិនដឹងឆ្នាំប៉ុន្មានទេ យើងនេះមុនអន្លង់វែង អន្លង់វែងចុងក្រោយខែប៉ុន្មាន ឆ្នាំប៉ុន្មានទេ ។

ប៊ុនថន : ៩៧លោកពូ?

ខ្ញុំ : បាទ!ហ្នឹងហើយ ។

ប៊ុនថន ៖ ខាងម៉ាខ្សែនោះ៩៦?

ទុំ ៖ បាទ!ម៉ាខ្សែដូចក្រោយនេះទេ អីក៏អន្លង់វែង ។

ប៊ុនថន ៖ បាទ!អញ្ចឹងពូ ចេញម៉ោពីជំរុំឬនៅពេលចូលសមាហរណកម្មហ្នឹង?

ទុំ ៖ ចេញហើយ ខ្ញុំចេញម៉ោហើយ ម៉ោនៅយើងសំឡូតដែរ ប៉ុននៅដីយើងជិតសាលាស្រុកសំឡូត នៅខាងត្បូងសាលាស្រុកសំឡូត ។

ប៊ុនថន ៖ បាទ!ឆ្នាំប៉ុន្មានបានពូម៉ោរស់នៅនេះ?

ទុំ ៖ ខ្ញុំម៉ោឆ្នាំ៩០ប៉ុន្មានទេ សមាហរណកម្មបានបន្តិចខ្ញុំមៅ ពេលដែលយើងត្រូវគ្នាចប់អស់ហើយហ្នឹងខ្ញុំម៉ោនៅនេះ ។

ប៊ុនថន ៖ ច្រើនទេពូម៉ោនៅហ្នឹង?

ទុំ ៖ ច្រើន ។

ប៊ុនថន ៖ ប៉ុន្មានគ្រួសារពូ?

ទុំ ៖ អ៊ូ!រាប់រយរាប់ពាន់ មនុស្សស្រុកយើង ស្រុកវាលវែងហ្នឹងម៉ោនៅហ្នឹង ។

ប៊ុនថន ៖ បាទ!ម៉ោពីសំឡូតទាំងអស់?

ទុំ ៖ បាទ!ភាគច្រើនម៉ោពីសំឡូត ។

ប៊ុនថន ៖ ម៉ោដល់នេះគេបែងចែកម៉េចទៅពូ ដូចថាជាស្រុក ភូមិ ឃុំអីហ្នឹងគេមានស្រាប់ឬក៏មិនទាន់បែងចែកទេ?

ទុំ ៖ អត់ទេ!គេរៀបចំហើយៗ រដ្ឋាភិបាលរៀបចំហើយអស់ហើយ ឧទាហរណ៍ភូមិ ឃុំហ្នឹងទៅស្រុកហ្នឹងទៅ យើងគ្រាន់តែម៉ោហ្នឹងនៅហ្នឹងនៅឃុំអន្លង់រាប ភូមិៗដីក្រហមអញ្ចឹងទៅ ។

ប៊ុនថន ៖ បាទ!ហើយចុះដីធ្លីបែងចែកម៉េចទៅ?

ទុំ ៖ ដីធ្លីជំនាន់ហ្នឹងយើងស្ដាប់កកើតរដ្ឋាភិបាលរស់នៅកន្លែងណា រក្សានៅកន្លែងហ្នឹងទៅណា៎ចេះតែបបួលគ្នាកាប់បបួលគ្នារាបអញ្ចឹងទៅដី កាលមុនអត់ទាន់មានអីទេ បរិស្ថានក៏មិនទាន់មានអីដែរ និយាយរួមវាដោយឡែក ក្រោយពីជំនាន់ខ្មែរក្រហមចប់ទៅគ្មានទាន់មានអ្នកណានេះ មានតែអ្នកដឹកនាំចាស់អញ្ចឹងចេះតែបបួលគ្នានៅហ្នឹងរៀបចំអីហ្នឹងកាប់ដីកាប់ធ្លីហ្នឹងទៅ ។

ប៊ុនថន ៖ បាទ!មានកំណត់យ៉ាងម៉េចដែរពូ?

ខ្ញុំ ៖ កាលមុនដំបូងអត់កំណត់ទេ តែឥឡូវកំនត់ យើងមុនដំបូងមិនទាន់មានមនុស្សផង ព្រោះផ្លូវមិនទាន់មានផងដើរហ្នឹង សុទ្ធតែមីនអីហ្នឹង ។

ប៊ុនថន ៖ គ្រាប់មីនខាងណាដាក់ពូ?

ខ្ញុំ ៖ ជំនាន់កាលយើងវៃគ្នា យើងពិបាកសន្និដ្ឋានថាខាងរដ្ឋាភិបាលវៀតណាមអ្នកដាក់ខ្លះ ខាងខ្មែរក្រហមក៏ខ្លះអញ្ចឹងទៅណា៎ មានច្របូកច្របល់គ្នា ។

ប៊ុនថន ៖ បាទ!ចុះមកដល់ដំបូងពូធ្វើដែរលោកពូ?

ខ្ញុំ ៖ ខ្ញុំធ្វើចំការ ហើយខ្ញុំធ្វើប៉ូលីសជំនាន់ហ្នឹងគេឲ្យធ្វើប៉ូលីស មេស្រុកវាលវែងទីមុីត្រែត បានមួយឆ្នាំ ។

ប៊ុនថន ៖ អធិការប៉ូលីសពូ?

ខ្ញុំ ៖ អត់ទេ!ធ្វើកូនគេដែរ ខាងផ្នែកប៉ូលីស រុីត្រែត ម៉ោនេះខ្ញុំធ្វើប៉ូលីសផង ខ្ញុំធ្វើចំការផង ការងារមួយផ្នែកជួយរដ្ឋាភិបាលក្នុងការងារសន្តិសុខអញ្ចឹងទៅ មួយផ្នែកទៀតក៏យើងបន្តបង្កើនផលដោះស្រាយជីវភាពខ្លួនយើងអញ្ចឹងទៅ ។

ប៊ុនថន ៖ បាទៗ!

ខ្ញុំ ៖ បើមិនធ្វើអញ្ចឹង ចុះមានអីក្រៅពីហ្នឹង គ្មានជង្រុកគ្មានស្រូវ គ្មានស្រែគេណា ។

ប៊ុនថន ៖ បាទ!ហើយដុះសព្វថ្ងៃហ្នឹង រដ្ឋាភិបាលចែកឲ្យឬក៏ម៉ោចាប់នៅហ្នឹងម៉ង?

ខ្ញុំ ៖ តាមពិតរដ្ឋាភិបាលគ្រាន់តែជាអ្នកចង្អុលទិសឲ្យយើងជាអ្នករៀបចំឲ្យយើងនៅម៉ាជួរហ្នឹង ពង្រីកភូមិពង្រីកស្រុកទៅណា៎ អញ្ចឹងយើងម៉ោនៅកន្លែងនេះ យើងខំធ្វើខ្លួនយើង អញ្ចឹងនៅខំរកអាលឈើធ្វើផ្ទះធ្វើអីនៅទៅណា៎ ។

ប៊ុនថន ៖ បាទ!ពូមុនសមាហរណកម្ម ហើយក្រោយសមាហរណកម្មពូម៉ោដល់ទីនេះហើយដំបូង ជីវភាពការរស់នៅយ៉ាម៉េចដែរ ប្លែកម៉េចដែរពូបើតាមពូយល់?

ខ្ញុំ ៖ ដោយសារទឹក និយាយកត្តារស់នៅយើងនេះមានសិទ្ធសេរីភាព ចង់និយាយថា យើងមានពេលវេលា សម្រាប់បំរើគ្រួសារយើងស្រួលជាង ទោះបីការងាររដ្ឋក៏យើងកក់ក្តៅ ម្យ៉ាងស្ថិតក្នុងស្ថានភាពការដែលយើងសន្តិភាពហើយ ម្យ៉ាងទៀតយើងមានសិទ្ធមានអីៗសម្រាប់ដោះស្រាយជីវភាពក្នុងគ្រួសារសម្រាប់ផ្ទាល់ខ្លួនយើង មិនដូចយើងនៅក្នុងសង្គ្រាមបានសុំម៉ាពោះរស់ម៉ាខ្លួន អានេះសម្រាប់អានាគតកូនចៅ យើងខំធ្វើខ្លួនយើងទៅណា៎ រឿងសិទ្ធិសេរីភាពបើយើងទូលាយវាល្អមិនដូចជំនាន់ហ្នឹងទេ មិនដូចជំនាន់ខ្មែរក្រហម រស់ៗទាំងភ័យទៀត ។

ប៊ុនថន ៖ បាទ!មួយទៀតពូ បច្ចុប្បន្ននេះមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានតុលាការកូនកាត់ តុលាការដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលខ្មែរហើយជាមួយអង្គការសហប្រជាជាតិ ហើយសព្វថ្ងៃនេះមានចាប់ខ្លួនមេដឹកនាំខ្មែរក្រហម៤នាក់ មាន ខៀវ សំផន នួន ជា អៀង សារី ហើយ អៀង ធីរិទ្ធិ កំពុងឃុំខ្លួនហើយរង់ចាំថ្ងៃកាត់ ទោស ហើយលោកពូយល់យ៉ាងម៉េចដែរចំពោះការកាត់ទោសហ្នឹងពូ?

ទុំ ៖ បើសម្រាប់រូបខ្ញុំវាមិនមានបញ្ហាទេ សំខាន់បុគ្គលដែលធ្វើខុសកាត់ទៅតាមហ្នឹងទៅ ជំនាន់ហ្នឹងប្រជាជនទូទាំងប្រទេសរងគ្រោះ ខ្ញុំក៏រងគ្រោះដូចគេគ្នា និយាយខ្លីអញ្ចឹង ទៅ ។

ប៊ុនថន ៖ បាទៗ!

ទុំ ៖ ព្រោះអាហ្នឹងរឿងគាត់ដឹកនាំប៉ះពាល់ដល់ប្រជាពលរដ្ឋ ទទួលទោសទៅតាមហ្នឹងមិនមែនតែខ្ញុំទេ ម្យ៉ាងវាថាធ្វើទាំងមិនចិត្តមិនពេញចិត្តម្ល៉េះរបបដូចគ្នាប៉ុនធ្វើដើម្បីរស់ ប៉ុនឥឡូវយើងឲ្យគេកាត់ទោសទៅតាមកំហុសដែលគាត់ធ្វើទៅ គ្មានទាក់ទិនអីនឹងយើង ។

ប៊ុនថន ៖ បាទៗ!

ទុំ ៖ ការងារគាត់អ្នកបង្កើតគាត់អ្នកទទួល ។

ប៊ុនថន ៖ បាទ!អញ្ចឹងលោកពូមានអីចង់បន្ថែមទៀតទេលោកពូ?

ទុំ ៖ ខ្ញុំអត់មានអីចង់បន្ថែមទៀតទេ ។

ប៊ុនថន ៖ អញ្ចឹងខ្ញុំអរគុណច្រើនលោកពូ ។

ទុំ ៖ បាទៗ!

**ចប់**